## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩

**សេចក្តីសំរេច លេខ ៤៦ សសរ**

**ស្តីពីការ តែងតាំងទីប្រឹក្សានាយករដ្ឋមន្ត្រី**

**នៃ ព្រះរាជាណាចក្រកម្ពុជា**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណូមពរការងារចាំបាច់ របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : តែងតាំងលោក ឡេស្លី ឡេក ជាទីប្រឹក្សាសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ ២ : លោក ឡេស្លី ឡេក ត្រូវអនុវត្តនូវសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ១៩៩៩

**សេចក្តីសំរេច លេខ ៤៧ សសរ**

**ស្តីពីការបង្កើតគណៈកម្មការដោះស្រាយបាតុភាព**

**បញ្ហាដីធ្លី នៅតាមបណ្តាខេត្ត-ក្រុងទូទាំងប្រទេស**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការដោះស្រាយបញ្ហាព្រំដែន បញ្ហាដីធ្លី នៅទូទាំងប្រទេស ដែលមានសមាសភាព ដូចខាងក្រោម ÷

១-ឯកឧត្ដម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន

២-ឯកឧត្ដម គន់ គីម ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី អនុប្រធានទី១

៣-ឯកឧត្ដម ហ៊ុន ថៃម រដ្ឋលេខាធិការក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អនុប្រធាន

៤-ឯកឧត្ដម ចាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន

៥-ឯកឧត្ដម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៦-ឯកឧត្ដម ចំរួនតុខ អ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សមាជិក

៧-ឯកឧត្ដម ទ៊ុន ង៉ុយ អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

៨-ឯកឧត្ដមប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង សមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្ដម ម៉ុល លឹម អគ្គាធិការរងទី១រដ្ឋបាលនិងនគរបាលក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្ដម ជុំ ភារ៉ាណាល់ ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី អនុប្រធាន

៣-ឧត្ដមសេនីយ៍ទោ សិទ្ធ ឌី មេបញ្ជាការរងកងទ័ពជើងគោក អនុប្រធាន

៤-ឯកឧត្ដមប្រតិភូរាជរដ្ឋាភិបាល អភិបាលរងខេត្ត-ក្រុង សមាជិក

៥-ឧត្ដមសេនីយ៍ទោ ម៉ឹម សុផាន ប្រធានឧទ្ទកាល័យអគ្គបញ្ជាការ ក.ឃ.ខ.ភ.ម. សមាជិក

៦-ឧត្ដមសេនីយ៍ទោ កែវ តាំ ប្រធាននាយកដ្ឋានអធិការកិច្ច ក្រសួងការពារជាតិ សមាជិក

៧-លោក យ៉ា ឡេងហារី ជំនួយការឯកឧត្ដមទេសរដ្ឋមន្ត្រី

| | | |
|---|---|---|
| | អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨-លោក ខឹម ជា សោភ័ណ្ឌ | អគ្គលេខាធិការក្រសួងទំនាក់ទំនង ជាមួយព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច | សមាជិក |
| ៩-លោក គុល ទិវេទ្យ | ប្រធានអធិការកិច្ចរដ្ឋបាលក្រសួងមហាផ្ទៃ | សមាជិក |
| ១០-លោក លឹម ទាន់ | ប្រធាននាយកដ្ឋានសុរិយោដី ក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១-លោក ស៊ុន សុខ | ប្រធាននាយកដ្ឋានរដ្ឋបាល ក្រសួង ព័ត៌មាន | សមាជិក |
| ១២-លោក សួស សំអាត | មន្ត្រីនៃនាយកដ្ឋានកិច្ចការព្រហ្មទ័ណ្ឌ និងរដ្ឋប្បវេណីក្រសួងយុត្តិធម៌ | សមាជិក |
| ១៣-លោក ហាស សុខ | អនុប្រធាននាយកដ្ឋាន[illegible] ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

ប្រការ ៣ : គណៈកម្មការនេះមានភារកិច្ច :

- ចុះត្រួតពិនិត្យ និងលើកវិធានការដោះស្រាយរាល់ការរំលោភកម្មសិទ្ធិភាព ឬវិវាទពាក់ព័ន្ធដីធ្លីដែលកើតឡើងនៅតាមបណ្តាខេត្ត-ក្រុង ។
- ធ្វើរបាយការណ៍ អំពីវិធានការដោះស្រាយ និងលទ្ធផលនៃការងារជូនរាជរដ្ឋាភិបាល ។
- ក្នុងករណីកើតមានបាតុកម្ម កូដកម្ម ពាក់ព័ន្ធនឹងបញ្ហាដីធ្លីនៅមុខព្រះបរមរាជវាំង មុខអគារព្រឹទ្ធសភា មុខអគាររដ្ឋសភា មុខទីស្តីការគណៈរដ្ឋមន្ត្រី និងនៅតាមទីសាធារណៈ ខេត្ត-ក្រុងផ្សេងៗទៀត គណៈកម្មការនេះ ត្រូវបញ្ជូនមន្ត្រីជំនាញទៅជួបពិភាក្សាជាមួយតំណាង បាតុករ កូដករ ដើម្បីដោះស្រាយបញ្ហាដោយសន្តិវិធី ។ ទន្ទឹមនឹងនោះ ត្រូវរាយការណ៍ជាបន្ទាន់មករាជរដ្ឋាភិបាល ដើម្បីចាត់វិធានការសមស្រប ។

ប្រការ ៤ : សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ។ គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សំរាប់សំរួលការងារ ។

ប្រការ ៥ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័ន ពាក់ព័ន្ធ

ក្រសួងរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និង អគ្គនាយកអស់លោកដែលមានឈ្មោះក្នុងប្រការ១ និងប្រការ២ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ៣- សារាចរ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩

### សារាចរ លេខ ០៦ ស.រ

### ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និង ការកែទម្រង់សេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ

***

យោងតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានប្រកាសនៅចំពោះមុខសម័យប្រជុំពេញអង្គ នៃរដ្ឋសភា នាថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ និងសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៩៨ ជាបន្តបន្ទាប់មក រាជរដ្ឋាភិបាលបានលើកវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និង កែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលប្រមាក់ប្រឡាជាមួយនឹងវិធានការកំណែទម្រង់មុខសញ្ញាទៀត គឺការកែទម្រង់រដ្ឋបាល ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់កងទ័ព-នគរបាល ។រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការដូចខាងក្រោមនេះ ដើម្បីអនុវត្តច្បាប់ និង បទបញ្ញត្តិទាំងឡាយណាដែលពាក់ព័ន្ធនឹងកំណែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ អោយមានប្រសិទ្ធភាព និងប្រកបដោយចីរភាព ។

### I-ខាងវិស័យសេដ្ឋកិច្ច

គោលដៅជាគន្លឹះ នៃការប្រតិបត្តិគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលគឺ ៖

១-បង្កើនល្បឿនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ដើម្បីលើកកំពស់ជីវភាពសំភារៈ និងដើម្បីបង្កើនការផ្តល់ជូនប្រជាជនកម្ពុជាគ្រប់រូប ។ ខិតខំធ្វើអោយបានសំរេចជាជំហានៗ នូវគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។